**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

លេខ ០១៤ ទសកន

CAMBODIA
Kingdom of Wonder
feel the warmth

ថ្ងៃ ចន្ទ ៤រោច ខែ អាសាឍ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០២០

## សេចក្តីណែនាំ

## ស្តីពី

## ការអនុញ្ញាតឱ្យរៀបចំព្រឹត្តិការណ៍ ឬការប្រកួតដណ្តើមពានរង្វាន់កីឡាវាយកូនគោលជាជំហានៗ

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ (COVID-19) ស្តីពីការដាក់ឱ្យដំណើរការឡើងវិញនូវវិស័យកីឡាជាជំហានៗ ក្រសួងទេសចរណ៍ អនុញ្ញាតឱ្យម្ចាស់ និងអ្នកគ្រប់គ្រងទីលានវាយកូនគោល អាចរៀបចំជាព្រឹត្តិការណ៍ ឬការប្រកួតដណ្តើមពានរង្វាន់កីឡាវាយកូនគោលឡើងវិញជាជំហានៗ ប៉ុន្តែត្រូវអនុវត្តតាមលក្ខខណ្ឌសុវត្ថិភាពមួយចំនួនដូចខាងក្រោម៖

១. ការរៀបចំព្រឹត្តិការណ៍ ឬការប្រកួតដណ្តើមពានរង្វាន់កីឡាវាយកូនគោល មិនអនុញ្ញាតឱ្យមានចំនួនកីឡាករ និងគណៈកម្មការរៀបចំការប្រកួតច្រើនលើសពី ១00នាក់ ក្នុងពេលតែមួយ និងមិនអនុញ្ញាតឱ្យមានទស្សនិកជន។

២. រាល់ការរៀបចំព្រឹត្តិការណ៍ និងការប្រកួតត្រូវគោរពតាមនិយាមបច្ចេកទេស ដើម្បីធានាសុវត្ថិភាព។

៣. ត្រូវរៀបចំបាញ់ទឹកអាល់កុលសម្លាប់មេរោគនៅច្រកចូល និងត្រួតពិនិត្យកម្តៅបុគ្គលិកបម្រើការ កីឡាករ មុនអនុញ្ញាតឱ្យចូលក្នុងបរិវេណទីលានវាយកូនគោល។

៤. ត្រូវរក្សាគម្លាតសុវត្ថិភាពស្របតាមការណែនាំរបស់ក្រសួងសុខាភិបាល (យ៉ាងតិច១.៥០ម៉ែត្រ) និងធ្វើការសម្អាតសម្ភារៈឧបករណ៍វាយកូនគោលទាំងអស់ជាមួយទឹកអាល់កុលជាប្រចាំ មុនពេល អំឡុងពេល និងក្រោយពេលប្រើប្រាស់ ដើម្បីសម្លាប់មេរោគ និងហាមចាប់ដៃស្វាគមន៍ ដោយជំនួសការលើកដៃសំពះគ្នាទៅវិញទៅមក។

៥. បុគ្គលិកត្រូវពាក់ម៉ាស់ឱ្យបានត្រឹមត្រូវគ្រប់ពេលវេលា និងធ្វើការត្រួតពិនិត្យ ជូតសម្អាតសម្ភារៈឧបករណ៍វាយកូនគោលទាំងអស់ជាមួយទឹកអាល់កុលមុនពេលដាក់ចូលទៅក្នុងរថយន្តវាយកូនគោល (Golf Cart)។

៦. ត្រូវរៀបចំទីលានវាយកូនគោល និងគ្រប់គ្រងការរៀបចំព្រឹត្តិការណ៍ ឬការប្រកួតដណ្តើមពានរង្វាន់កីឡាវាយកូនគោលឱ្យបានត្រឹមត្រូវតាមវិធាន និងការណែនាំរបស់ក្រសួងសុខាភិបាល ដើម្បីធានាបាននូវសុវត្ថិភាពក្នុងការទប់ស្កាត់ការចម្លងជំងឺកូវីដ១៩ (COVID-19) រលកទី២។

**ក្រសួងទេសចរណ៍**

អគារលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org